

សង្ខេបគោលនយោបាយ

# ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសិស្សដែលមានពិការភាព៖

## ករណីគរុនិស្សិតគ-ថ្លង់ និងពិការភ្នែកនៅ វិទ្យាស្ថានជាតិអប់រំពិសេស (NISE) និង សិស្សនៅវិទ្យាល័យអប់រំពិសេសនៅកម្ពុជា

Australian Aid

ពន្លក ចំណេះ

The Asia Foundation

## អំណះអំណាង

ការសិក្សានេះទទួលបានការគាំទ្រពី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលលើកឡើងនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី ឬវិទ្យាស្ថានជាតិអប់រំពិសេសឡើយ។

© មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវ និងនវានុវត្តន៍ ២០២៣

# អនុសាសន៍សម្រាប់គោលនយោបាយ

អនុសាសន៍គោលនយោបាយទាំងនេះ គឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវស្ដីពី "ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសិស្សដែលមានពិការភាព៖ករណីគរុនិស្សិតគ-ថ្លង់ និងពិការភ្នែកនៅវិទ្យាស្ថានជាតិអប់រំពិសេស (NISE) និងសិស្សនៅវិទ្យាល័យអប់រំពិសេសនៅកម្ពុជា"។ សង្ខេបគោលនយោបាយនេះនឹងស្នើជម្រើសគោលនយោបាយចំនួនប្រាំមួយ៖

### ផ្ដល់ជំនួយសង្គម

និងលើកកម្ពស់ការយល់ដឹងអំពីរបៀបជួយគាំទ្រដល់យុវជន និងកុមារដែលមានពិការភាពក្នុងគ្រាមានវិបត្តិ

### បង្កើតក្រុមសិក្សាតូចៗ

ដែលមានកុមារមកជុំគ្នាដើម្បីរៀនសូត្រ និងប្រាស្រ័យទាក់ទងគ្នា។ ក្រុមសិក្សាតូចៗនេះ ត្រូវបានប្រើប្រាស់ចំពោះសិស្សដែលមិនមានអ៊ីនធឺណិត ឬមិនមានជំនួយពីមនុស្សពេញវ័យនៅផ្ទះរបស់ពួកគេ

### កាត់បន្ថយខ្លឹមសារដែលនឹងត្រូវបង្រៀន

និងកែសម្រួលវិធីសាស្រ្តបង្រៀន គឺជាកត្តាមួយកំណត់អំពីភាពជោគជ័យរបស់សិស្សគ-ថ្លង់ក្នុងការទទួលបានការអប់រំដោយការរៀនពីចម្ងាយតាមអ៊ីនធឺណិត

### ផ្ដល់វគ្គបណ្ដុះបណ្ដាលផ្លូវការដល់សិស្ស

ពីអ្នកជំនាញបច្ចេកវិទ្យាព័ត៌មាន ដោយមានអ្នកបកប្រែពីការប្រើប្រាស់ប្រព័ន្ធអនឡាញ មុននឹងចូលសិក្សាក្នុងថ្នាក់ដំបូង

### ផ្ដល់ឧបករណ៍

និងបច្ចេកវិជ្ជាដែលមានគុណភាពខ្ពស់ មានភាពចាំបាច់ និងកែលម្អលទ្ធភាពប្រើប្រាស់ ក៏ដូចជា ការប្រើប្រាស់សម្ភារៈសិក្សា។ បើទោះបីជាស្ថាប័នជាច្រើនបានធ្វើមាតិកាឌីជីថលយ៉ាងណាក៏ដោយ ក៏សិស្សមិនអាចចូលទៅប្រើប្រាស់បានដែរ ដោយសារកង្វះខាតនៃអត្ថបទ និងបញ្ហាសំឡេង ព្រមទាំងមានបញ្ហាផ្សេងៗទៀត

### ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការ

និងភាពជាដៃគូដោយបង្ហាញពីតួនាទីសំខាន់របស់រាជរដ្ឋាភិបាល គ្រូបង្រៀន ឪពុកម្ដាយ និងអ្នកឯកទេសក្នុងការកែលម្អលទ្ធផលអប់រំសម្រាប់សិស្សគ-ថ្លង់

# សេចក្ដីផ្ដើម

## នៅប្រទេសកម្ពុជាមាន

# ៦៨៩.៥៣២ នាក់

ជាជនមានពិការភាព

| | | |
|---|---|---|
| **៧៤.៣%** | **១៩.៤%** | **៦.៣%** |
| ជាជនដែលមានពិការភាព ដោយផ្នែក | ជាជនដែលមានពិការភាព ធ្ងន់ធ្ងរ | ជាជនដែលមានពិការភាព ទាំងស្រុង |

ជនមានពិការភាពត្រូវបានការពារដោយអនុសញ្ញាអន្តរជាតិ និងច្បាប់ក្នុងស្រុក ក្នុងគោលបំណងធានាថាជនដែលមានពិការភាពអាចទទួលបានសេរីភាព និងសិទ្ធិពេញលេញ រួមមានសិទ្ធិមិនត្រូវបានគេរើសអើង សិទ្ធិក្នុងការចូលរួមនិងការបញ្ចូលក្នុងសង្គម សិទ្ធិទទួលបានសមភាពក្នុងឱកាស សិទ្ធិទទួលបាននិងការត្រូវបានចាត់ទុកថាស្មើគ្នា និងសេចក្ដីថ្លៃថ្នូររបស់ពួកគេត្រូវបានគោរពក្នុងនាមជាមនុស្ស។



ក្នុងគោលបំណងដូចគ្នានេះដែរ ច្បាប់របស់ប្រទេសកម្ពុជា ស្ដីពីការការពារ និងការលើកកម្ពស់សិទ្ធិជនដែលមានពិការភាព ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។

សិទ្ធិរបស់ជនដែលមានពិការភាពក្នុងការអប់រំត្រូវបានការពារ និងសម្រេចបានតាមរយៈលិខិតូបករណ៍ច្បាប់ផ្សេងទៀត រួមមានអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនដែលមានពិការភាព រដ្ឋធម្មនុញ្ញនៃកម្ពុជា និងច្បាប់របស់កម្ពុជាស្ដីពីការការពារ និងការលើកកម្ពស់សិទ្ធិជនដែលមានពិការភាព។ ជនដែលមានពិការភាពត្រូវបានលើកកម្ពស់តាមរយៈគោលនយោបាយផ្សេងៗ រួមទាំងយុទ្ធសាស្ត្រជាតិស្ដីពីជនដែលមានពិការភាពឆ្នាំ ២០១៩-២០២៣។

ពាក់ព័ន្ធនឹងការលើកកម្ពស់ការអប់រំជនដែលមានពិការភាពនៅកម្ពុជា ការអប់រំពិសេសត្រូវបានយកចិត្តទុកដាក់ដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈការអនុម័តគោលនយោបាយស្តីពីការអប់រំសម្រាប់កុមារដែលមានពិការភាពនៅក្នុងឆ្នាំ២០០៨ ហើយដែលត្រូវបានកែសម្រួលទៅជាគោលនយោបាយស្តីពីការអប់រំបរិយាប័ន្ន ដោយក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងឆ្នាំ២០១៨។

ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីដើមឆ្នាំ២០២០មក បានបង្កឱ្យមានវិបត្តិសុខភាពសាធារណៈ ហើយជាលទ្ធផលនាំឱ្យមានផលវិបាកសង្គម និងសេដ្ឋកិច្ចសម្រាប់បុគ្គល ពាណិជ្ជករ និងរាជរដ្ឋាភិបាល។

## វិបត្តិនេះប៉ះពាល់យ៉ាងខ្លាំងដល់ជនមានពិការភាព ដោយសារតែ

១ ការងាររបស់ពួកគេ ត្រូវបានព្យួរ ឬបញ្ឈប់ដោយសារការផ្អាក ឬបិទអាជីវកម្ម

២ វិធានការរក្សាគម្លាតសង្គម

៣ ការរឹតបន្តឹងការធ្វើដំណើរ

៤ ការរឹតបន្តឹងការជួបជុំ ការបិទខ្ទប់

៥ ការបិទសាលារៀន

៦ និងវិធានការបង្ការជំងឺរាតត្បាតកូវីដ-១៩ ផ្សេងៗជាច្រើនទៀត

វិបត្តិនេះអាចនឹងប៉ះពាល់ដល់សិទ្ធិ និងអត្ថប្រយោជន៍ដែលត្រូវបានផ្តល់ជូនជនដែលមានពិការភាព។ ជំងឺកូវីដ-១៩ ក៏បានជះឥទ្ធិពលលើវិស័យអប់រំជាច្រើនមុខ ដែលអាចជាបញ្ហាប្រឈមក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចចិត្តបិទគ្រឹះស្ថានសិក្សាទាំងអស់ រួមទាំងសាលារៀនរដ្ឋ និងឯកជន នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។ ការបិទសាលាបានបណ្តាលឱ្យមានការរំខានដល់ការសិក្សានៅសាលាទាំងអស់ក្នុងប្រទេសកម្ពុជាចំនួន **១៣.៤៨២ សាលា** ដែលប៉ះពាល់ដល់សិស្សចំនួន **៣.២១០.២៨៥ នាក់ (៥០% ជាស្ត្រី) និងគ្រូបង្រៀន ៩៣.២២៥ នាក់** (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២១)។ នៅក្នុងវិស័យអប់រំ សិស្សដែលមានពិការភាពត្រូវបានគេរកឃើញថា បានទទួលរងផលប៉ះពាល់កាន់តែខ្លាំងដោយជំងឺរាតត្បាតចំពោះការរស់នៅ និងការរៀនសូត្ររបស់ពួកគេ។ ការវិភាគនៅក្នុងអត្ថបទនេះ គឺផ្អែកលើករណីសិក្សានៅវិទ្យាស្ថានជាតិអប់រំពិសេស (NISE) និងវិទ្យាល័យអប់រំពិសេសចំនួន៥ នៅប្រទេសកម្ពុជា។

# វិធីសាស្ត្រស្រាវជ្រាវ

## ការសិក្សាពិគ្រោះលើឯកសារ

## ការវិភាគទិន្នន័យបន្ទាប់បន្សំ

## ការសម្ភាសន៍បែបគុណវិស័យ

ការសិក្សានេះពិនិត្យមើលបទប្បញ្ញត្តិច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រទាក់ទងនឹងពិការភាព និងគាំទ្រដល់ជនដែលមានពិការភាពក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩។ លើសពីនេះទៀត អត្ថបទដែលបានបោះពុម្ពផ្សាយទាក់ទងនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសិស្សដែលមានពិការភាពក្នុងទម្រង់ជាអត្ថបទទិនានុប្បវត្តិ ឯកសារបោះពុម្ពផ្លូវការផ្សេងៗ គេហទំព័រ និងរបាយការណ៍ ដើម្បីបញ្ជាក់អំពីទិដ្ឋភាពជាទូទៅ និងភាពខុសគ្នានៃការរកឃើញលើផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសិស្សដែលមានពិការភាពនៅប្រទេសផ្សេងៗ និងនៅប្រទេសកម្ពុជា ក៏ត្រូវបានពិនិត្យផងដែរ។ ជាចុងក្រោយសិក្ខាសាលាត្រូវបានរៀបចំឡើងដើម្បីផ្ទៀងផ្ទាត់ និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវជាមួយនឹងភាគីពាក់ព័ន្ធ។

- ការពិនិត្យមើលឯកសារច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រទាក់ទងនឹងពិការភាព និងការឆ្លើយតបនឹងជំងឺកូវីដ-១៩ សម្រាប់ពិការភាព
- ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងការពិភាក្សាជាក្រុមជាមួយក្រុមគោលដៅ (សមាជិកគ្រប់គ្រងសាលាចំនួន ៩នាក់ គ្រូបង្រៀនចំនួន ២២នាក់ សិស្សគ-ថ្លង់ចំនួន ៣៥នាក់ និងពិការភ្នែកចំនួន ៣៣នាក់ មកពីវិទ្យាល័យចំនួន៥ សម្រាប់ការអប់រំពិសេស និងគ្រូបណ្តុះបណ្តាលចំនួន ២១នាក់មកពីវិទ្យាស្ថានជាតិអប់រំពិសេស NISE និងឪពុកម្តាយរបស់សិស្សចំនួន ១០នាក់។)
- ការរកឃើញពីបទសម្ភាសន៍ត្រូវបានដាក់ជាក្រុមទៅជាប្រធានបទ។
- ការរកឃើញនឹងត្រូវពិភាក្សាជាមួយនឹងទ្រឹស្តី របាយការណ៍ អត្ថបទទិនានុប្បវត្តិ គេហទំព័រ។ល។
- សិក្ខាសាលាផ្សព្វផ្សាយ/ពិគ្រោះយោបល់

# ការរកឃើញសំខាន់ៗ

## ស្ថានភាពសិស្សដែលមានពិការភាពនៅប្រទេសកម្ពុជា

សិស្សគ-ថ្លង់ និងសិស្សពិការភ្នែកឬខ្សោយគំហើញបានជួបប្រទះផលប៉ះពាល់ទាក់ទងនឹងការរស់នៅ និងការសិក្សារបស់ពួកគេ ពីជំងឺរាតត្បាតកូវីដ-១៩។ សាលារៀនទាំងអស់ត្រូវបានបិទ ហើយប៉ុន្មានខែក្រោយមក របៀបរៀនតាមអ៊ីនធឺណិតត្រូវបានណែនាំ។ ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំកម្មវិធីទូរទស្សន៍ និងវីដេអូឃ្លីប ដើម្បីជួយដល់ការសិក្សារបស់សិស្ស។

### របៀបរៀនតាមអ៊ីនធឺណិតដើម្បីជាជំនួយដល់សិស្សពិការភ្នែក និងសិស្សគ-ថ្លង់

- កម្មវិធីទូរទស្សន៍
- វីដេអូឃ្លីប

លើសពីនេះ លោកគ្រូអ្នកគ្រូត្រូវបានលើកទឹកចិត្តឱ្យផលិតវីដេអូខ្លីៗ ដើម្បីផ្ញើជូនសិស្ស។

### របៀបនៃការបង្រៀន ឬការប្រាស្រ័យទាក់ទងគ្នារវាងគ្រូ និងសិស្សត្រូវបានធ្វើឡើងតាមរយៈ

- ផ្ញើសារម៉េសេនជ័រ
- តេលេក្រាម

គ្រូបានផ្ញើឃ្លីបវីដេអូ និងសម្ភារៈសិក្សាដល់សិស្សដោយប្រើកម្មវិធីទាំងពីរ។ ផ្អែកលើកិច្ចសម្ភាសន៍ជាមួយសិស្ស លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា សម្ភារៈទាំងនេះមិនបានបំពេញតម្រូវការពិសេសរបស់សិស្សមានពិការភាពទេ។

មិនមានការណែនាំជាពិសេសណាមួយពីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការដោះស្រាយជាមួយសិស្សដែលមានពិការភាពដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់កូវីដ-១៩ឡើយ។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាស្ថានជាតិអប់រំពិសេស (NISE) និងវិទ្យាល័យចំនួន ៥ផ្សេងទៀត សម្រាប់ការអប់រំពិសេស បានធ្វើតាមការណែនាំរបស់រដ្ឋាភិបាលដែលអនុវត្តចំពោះវិទ្យាល័យធម្មតា ដែលមានដូចជា ការរក្សាគម្លាតសង្គម និងការពង្រឹងលើវិធានអនាម័យរបស់សិស្ស។ មានការគាំទ្រតិចតួចណាស់សម្រាប់ការរស់នៅ និងការរៀនសូត្ររបស់សិស្សដែលមានពិការភាព។

## ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើអារម្មណ៍ និងសុខុមាលភាពរបស់សិស្ស

សិស្សពិការភ្នែក និងសិស្សគ-ថ្លង់ មានអារម្មណ៍ថាពិបាកផ្លាស់ទី នៅក្នុងអំឡុងពេលនៃការរក្សាគម្លាត និងការរឹតត្បិតទំនាក់ទំនងសង្គម។ វិធានការនេះក៏បណ្ដាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់សិស្សដែលមានពិការភាពផងដែរ។ ការឃ្លាតឆ្ងាយពីសង្គមគឺជាបញ្ហាប្រឈមយ៉ាងខ្លាំងសម្រាប់សិស្សពិការភ្នែក ដោយសារពួកគេត្រូវការសេវាជាក់លាក់សម្រាប់ការធ្វើបំលាស់ទីរបស់ពួកគេ។ ក្នុងអំឡុងពេលនៃការរឹតបន្តឹងដោយសារជំងឺកូវីដ-១៩ សិស្សពិការភ្នែកជួបការលំបាកក្នុងការស្វែងរកទីតាំងគោលដៅ។ មិនខុសពីសិស្សពិការភ្នែកឡើយ សិស្សដែលមានបញ្ហាក្នុងការស្ដាប់ក៏ជួបការលំបាកក្នុងការធ្វើដំណើរទៅធ្វើការ ឬទៅរកវត្ថុចាំបាច់ផងដែរ។ ដោយសារការប្រាស្រ័យទាក់ទងគ្នាតម្រូវឱ្យប្រើភាសាសញ្ញា សិស្ស ឬសិក្ខាកាមដែលមានបញ្ហាលើការស្ដាប់មានអារម្មណ៍ថាពិបាកធ្វើចលនាជាងមនុស្សធម្មតា។ កុមារក៏ទទួលរងផលប៉ះពាល់ផ្លូវចិត្តនៃការរាតត្បាតកូវីដ-១៩ នេះផងដែរ។ ពួកគេជួបប្រទះការភ័យខ្លាច ភាពមិនប្រាកដប្រជា ការផ្លាស់ប្ដូរយ៉ាងច្រើនចំពោះទម្លាប់របស់ពួកគេ ភាពឯកោនៅក្នុងសង្គម រួមជាមួយនឹងកម្រិតខ្ពស់នៃភាពតានតឹងរបស់ឪពុកម្ដាយ។ ការឃ្លាតឆ្ងាយពីសង្គម ឬភាពឯកោក្នុងសង្គមបាននាំឱ្យមានការខ្វះខាតនូវទម្លាប់ប្រចាំថ្ងៃ។ ការរក្សាទម្លាប់មួយ ជំរុញឱ្យមានឆន្ទៈក្នុងការគោរពវិន័យ ក៏ដូចជាសុវត្ថិភាពចំពោះកុមារ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍផ្លូវចិត្ត និងអារម្មណ៍របស់ពួកគេ។

លើសពីនេះ ដោយសារតែការយល់ដឹងរបស់ពួកគេមានកម្រិតចំពោះព្រឹត្តិការណ៍នេះ ទាំងសិស្សពិការភ្នែក និងសិស្សដែលមានបញ្ហាក្នុងការស្ដាប់ មានការព្រួយបារម្ភយ៉ាងខ្លាំង។ ពិការភាពបានធ្វើឱ្យពួកគេព្រួយបារម្ភជាងសិស្សធម្មតា។ ពួកគេព្រួយបារម្ភខ្លាចឆ្លងមេរោគ។ ក្នុងន័យនេះ ពួកគេក៏មានយុទ្ធសាស្ត្រទប់ទល់ បើទោះបីជាមានកម្រិតក៏ដោយ។ សិក្ខាកាម និងនិស្សិតបានអះអាងថា ពួកគេខ្លាចឆ្លងមេរោគ ហើយពួកគេខ្លាចក្នុងការទាក់ទងជាមួយនឹងអ្នកដទៃ ឬមិត្តភ័ក្តិរបស់ពួកគេ។

ជាងនេះទៅទៀត សាលាអប់រំពិសេសបានផ្ដល់កន្លែងស្នាក់នៅ និងអាហារដល់សិស្សមកពីតំបន់ដាច់ស្រយាល និងសិស្សដែលត្រូវការជំនួយ។ សាលាបានផ្ដល់អាហារចំនួន ៣ពេលក្នុងមួយថ្ងៃដល់សិស្សដែលស្នាក់នៅក្នុងសាលា និងអាហារ ១ពេលដល់សិស្សដែលមិនបានស្នាក់នៅក្នុងសាលា។ ការរៀនពីផ្ទះមានន័យថា គ្រួសាររបស់ពួកគេត្រូវមើលថែទាំផ្ដល់អាហារអោយពួកគេ ដែលជាឧបសគ្គសម្រាប់គ្រួសារក្រីក្រ។ ជាងនេះទៅទៀត សិស្សានុសិស្សដែលអាចទទួលបានការងារដែលបានប្រាក់កម្រៃ មិនអើពើនឹងការរៀនតាមអ៊ីនធឺណិតឡើយ។ ក្រោយពីការបើកអោយចូលរៀនវិញ ពួកគេមិនចង់ត្រឡប់ទៅសាលាវិញទេ ព្រោះសប្បាយចិត្តនឹងប្រាក់ដែលរកបានពីការងារ។

# ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើការសិក្សារបស់សិស្ស

## ចំណេះដឹង និងលទ្ធភាពទទួលបានបច្ចេកវិទ្យាជំនួយមានកម្រិត

ដោយសារតែកង្វះការត្រៀមខ្លួនសម្រាប់ជំងឺរាតត្បាតដែលមិនអាចនឹកស្មានដល់ នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសផ្សេងទៀត ដែលជាប្រទេសមានការអភិវឌ្ឍតិចតួច ទាំងគ្រូបង្រៀន និងសិស្សានុសិស្ស មិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការប្រើប្រាស់បច្ចេកវិទ្យានោះទេ។ ដោយសារជំនាញបច្ចេកទេស ចំណេះដឹង និងភាពអាចរកបាននៃបច្ចេកវិទ្យាមានកម្រិត ទាំងគ្រូ និងសិស្សដែលទើបតែចាប់ផ្តើមរៀនប្រើប្រាស់បច្ចេកវិទ្យា បន្ទាប់ពីការផ្ទុះជំងឺរាតត្បាត បានក្លាយជាបញ្ហាប្រឈមយ៉ាងខ្លាំង។ សិស្សពិការភ្នែកទទួលបានអត្ថប្រយោជន៍ពី Google ដើម្បីជួយអានអត្ថបទ ប៉ុន្តែបច្ចេកវិទ្យាជំនួយនេះដំណើរការជាមួយអត្ថបទជាភាសាអង់គ្លេស។ ចំពោះអក្សរខ្មែរមិនទាន់ដំណើរការបានរលូនដូចភាសាអង់គ្លេសនៅឡើយទេ។

គ្រូក៏ខ្វះចំណេះដឹងបច្ចេកទេស ឬបទពិសោធន៍ជាមួយនឹងវេទិកាបង្រៀនតាមអ៊ីនធឺណិត ហើយមិនទទួលបានការបណ្តុះបណ្តាលណាមួយ បន្ទាប់ពីការបិទសាលា។ កម្មវិធីផ្ញើសារហ្វេសប៊ុក គឺជាវេទិកាទូទៅដែលពួកគេអាចប្រើប្រាស់សម្រាប់ការទំនាក់ទំនង និងការបង្រៀនសិស្ស។ គ្រូបានទទួលស្គាល់ថាការបង្រៀនតាមអ៊ីនធឺណិតមិនមានប្រសិទ្ធភាពដូចការបង្រៀនក្នុងថ្នាក់រៀនទេ ហើយមុខវិជ្ជាខ្លះត្រូវការអន្តរកម្ម និងការប៉ះដើម្បីធ្វើឱ្យសិស្សពិការភ្នែកអាចរៀនបាន ប៉ុន្តែសកម្មភាពទាំងនោះមិនអាចធ្វើបានតាមអ៊ីនធឺណិតឡើយ។

ដើម្បីជួយសិស្សានុសិស្សឱ្យបានរៀនក្នុងពេលមានជំងឺរាតត្បាត ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍បានថតមេរៀនជាវីដេអូ។ ទោះជាយ៉ាងណាក៏ដោយ លើកលែងតែការបកប្រែជាភាសាសញ្ញា វីដេអូទាំងនោះត្រូវបានថតទុកសម្រាប់សិស្សានុសិស្សជាទូទៅដោយមិនមានការយកចិត្តទុកដាក់ជាពិសេសចំពោះសិស្សដែលមានពិការភាពឡើយ។ វីដេអូនេះមិនបានឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សដែលមានពិការភាពនោះទេ។ ដោយខុសពីសិស្សដែលមានបញ្ហាក្នុងការស្តាប់ ការរៀនសូត្រគឺជាបញ្ហាប្រឈមសម្រាប់សិស្សភាគច្រើនដែលមានបញ្ហាភ្នែកមើលមិនឃើញ ហើយការរៀនតាមអ៊ីនធឺណិតបានបង្កបញ្ហាប្រឈមកាន់តែច្រើនសម្រាប់ពួកគេ។ សិស្សដែលមានបញ្ហាភ្នែកមើលមិនឃើញ ពឹងផ្អែកយ៉ាងខ្លាំងលើទំនាក់ទំនងរាងកាយដើម្បីរៀនមុខវិជ្ជាជាក់លាក់ដូចជា គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។ ទោះយ៉ាងណាក៏ដោយ ការប៉ះដើម្បីសិក្សានេះបានបាត់នៅក្នុងការរៀនតាមអ៊ីនធឺណិត។

## កង្វះឧបករណ៍ឆ្លាតវៃ និងការតភ្ជាប់អ៊ីនធឺណិត

ការទទួលបានឧបករណ៍ឆ្លាតវៃ និងអ៊ីនធឺណិតដើម្បីប្រើប្រាស់ នៅមានកម្រិតនៅឡើយសម្រាប់សិស្ស។ មានឧបករណ៍មួយចំនួនដែលផ្តល់ដោយម្ចាស់ជំនួយ បន្ថែមពីលើជំនួយរបស់គ្រួសារ ប៉ុន្តែលទ្ធភាពទទួលបានឧបករណ៍ទាំងនោះនៅមានកម្រិតខ្លាំងណាស់ បើប្រៀបធៀបទៅនឹងការទាមទាររបស់សិស្ស។ គុណភាពនៃឧបករណ៍ក៏នៅមិនល្អគ្រប់គ្រាន់ដែរ។ ចំណែកគ្រូបង្រៀនវិញ ពួកគេបានចាត់ទុកការបង្រៀនតាមប្រព័ន្ធអ៊ីនធឺណេតថាជាកិច្ចការដ៏លំបាកបំផុត ដោយសារពួកគេមិនទទួលបានការបណ្តុះបណ្តាលណាមួយទាក់ទងនឹងការបង្រៀនតាមអ៊ីនធឺណិត។

បន្ថែមពីលើភាពខ្វះខាតឧបករណ៍ឆ្លាតវៃ និងតម្លៃអ៊ីនធឺណិត កង្វះអ៊ីនធឺណិតដែលអាចទុកចិត្តនោះ បានធ្វើឱ្យសិស្សពិបាកចូលរៀនថ្នាក់អនឡាញ។

**ឧទាហរណ៍**

នៅពេលដែលវិទ្យាល័យអប់រំពិសេសបាត់ដំបង និងវិទ្យាល័យអប់រំពិសេសសៀមរាប ត្រូវបានតម្រូវឱ្យបិទជាបណ្ដោះអាសន្នអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ សិស្សត្រូវបានតម្រូវឱ្យរៀនតាមអ៊ីនធឺណិត។

ដើម្បីចូលរួមជាមួយសិស្សក្នុងការរៀនតាមអ៊ីនធឺណិត គ្រូបានទំនាក់ទំនងជាមួយឪពុកម្ដាយរបស់សិស្ស និងផ្ដល់ការណែនាំដល់ពួកគេ ដើម្បីធ្វើឱ្យប្រាកដថាសិស្សអាចរៀនតាមអ៊ីនធឺណិតបាន។ ទោះយ៉ាងណាក៏ដោយ តិចជាង៥០% នៃសិស្សអាចរៀនតាមអ៊ីនធឺណិតបាន ដោយសារកង្វះការតភ្ជាប់អ៊ីនធឺណិត និងឧបករណ៍ឆ្លាតវៃ។

## ប្រសិទ្ធភាពនៃការបង្រៀន និងរៀនតាមអ៊ីនធឺណិត

កង្វះបច្ចេកវិទ្យាដើម្បីផ្ដល់ជំនួយអ៊ីនធឺណិត និងវិធីសាស្ត្របង្រៀន បាននាំឱ្យមានការចោទជាសំណួរឡើងអំពីប្រសិទ្ធភាពក្នុងការបង្រៀនតាមអ៊ីនធឺណិត។ អ្នកគ្រប់គ្រងសាលាបានអះអាងថា វិធីសាស្ត្របង្រៀនដែលប្រើជាទូទៅមុនពេលជំងឺរាតត្បាតដោយគ្រូបណ្ដុះបណ្ដាល មិនមានប្រសិទ្ធភាពទាល់តែសោះនៅពេល អនុវត្តចំពោះការបង្រៀនតាមអ៊ីនធឺណិត។ សកម្មភាពជាច្រើនដូចជាការធ្វើការងារជាក្រុម ឬការពិភាក្សាជាក្រុមមិនត្រូវបានប្រើទាល់តែសោះ ដែលធ្វើឱ្យសិស្សធុញទ្រាន់ចំពោះការបង្រៀនតាមអ៊ីនធឺណិត និងមិនសូវមានអន្តរកម្ម។ ជាងនេះទៅទៀត ល្បឿននៃការបង្រៀនមានភាពយឺតយ៉ាវខ្លាំងបើធៀបនឹងការបង្រៀន និងរៀនដោយជួបគ្នាផ្ទាល់ក្នុងថ្នាក់ ហើយមានមេរៀនជាច្រើនមិនត្រូវបានយកមកបង្រៀនទេ។ គ្រូក៏មិនអាចគ្រប់គ្រងវត្តមានរបស់សិក្ខាកាមបានដែរ។ គ្រូបង្រៀនមួយចំនួនបានជួបនឹងបញ្ហាប្រឈមដោយត្រូវចំណាយបន្ថែមលើ អ៊ីនធឺណិតសម្រាប់ការបង្រៀន ដោយសារមិនមានជំនួយថវិកាសម្រាប់ការចំណាយបន្ថែមបែបនេះទេ។

សិក្ខាកាមគ្រូបង្រៀនត្រូវបានតម្រូវឱ្យប្រើ Zoom និងវេទិកាអនឡាញផ្សេងទៀតសម្រាប់ការងារ និងការបង្រៀន។ ទោះយ៉ាងណាក៏ដោយ មានភាពរអាក់រអួលខ្លាំង ពីព្រោះភាសាសញ្ញាតម្រូវឱ្យមានអន្តរកម្ម ដើម្បីធ្វើឱ្យទំនាក់ទំនងកាន់តែមានប្រសិទ្ធភាព ប៉ុន្តែអន្តរកម្មបែបនេះមិនបានកើតឡើងជាមួយនឹងការបង្រៀន និងការរៀនតាមអ៊ីនធឺណិតទេ។ គួបផ្សំនឹងការតភ្ជាប់អ៊ីនធឺណិតមិនស្ថិតស្ថេរ ការបង្រៀនតាមអ៊ីនធឺណិតពិតជាគ្មានប្រសិទ្ធភាពឡើយ។ ពួកគេត្រូវបានបញ្ជាក់ថា សិស្សស្ទើរតែទាំងអស់ដែលរស់នៅតំបន់ដាច់ស្រយាលមិនបានចូលរួមថ្នាក់អនឡាញនោះទេ។

## ផលប៉ះពាល់នៃជំងឺ-១៩ លើវិយាបថនៃការជ្រើសរើសរបស់មាតាបិតា

ត្រង់នេះពាក់ព័ន្ធនឹងការសម្របខ្លួនទៅនឹងបរិយាកាស និងវិធីសាស្ត្រនៃការបង្រៀន ដើម្បីធានាឱ្យមានការចូលរួមយ៉ាងពិតប្រាកដ និងមានតម្លៃរបស់កុមារ និងយុវជនទាំងអស់។ ធនធានហិរញ្ញវត្ថុមានកម្រិតសម្រាប់ការទិញឧបករណ៍ឆ្លាតវៃ និងការបង់ថ្លៃអ៊ីនធឺណិត រួមជាមួយនឹងភាពតានតឹងរបស់ឪពុកម្តាយ អាចបណ្តាលឱ្យមានការរើសអើងនៅពេលដែលឪពុកម្តាយផ្តល់អាទិភាព។ ឪពុកម្តាយនឹងពេញចិត្តកុមារធម្មតាជាជាងកុមារដែលមានពិការភាពក្នុងការអប់រំ។ ករណីនេះអាចត្រូវបានរកឃើញនៅក្នុងការសិក្សា។

> ការបង្រៀនតាមអ៊ីនធឺណិតដាក់សម្ពាធយ៉ាងខ្លាំងទៅលើឪពុកម្តាយ ដោយសារគ្រូបង្រៀនតម្រូវឱ្យឪពុកម្តាយផ្តល់ការថែទាំបន្ថែមសម្រាប់កូនៗរបស់ពួកគេ និងជួយកូនៗឱ្យបានរៀនអនឡាញស្ទើរតែទាំងអស់គ្នា។

នៅពេលសួរអំពីស្ថានភាពបន្ទាប់ពីចាប់ផ្តើមថ្នាក់រៀនដោយជួបគ្នាផ្ទាល់ឡើងវិញ នាយកសាលាបាននិយាយថា ទោះបីជាថ្នាក់រៀនដោយជួបគ្នាផ្ទាល់ត្រូវបានបន្តក៏ដោយ ឧបករណ៍អនឡាញមួយចំនួននៅតែត្រូវបានប្រើប្រាស់សម្រាប់ការបង្រៀន។ ឧទាហរណ៍ តេឡេក្រាមនៅតែត្រូវបានប្រើប្រាស់ដោយគ្រូ ដើម្បីចែកចាយឯកសារ និងកិច្ចការសម្រាប់សិក្ខាកាមរបស់ពួកគេ។ នេះអាចបញ្ជាក់បានថាការរៀនតាមអ៊ីនធឺណិតអាចទទួលបានអត្ថប្រយោជន៍ ប្រសិនបើគ្រូមានជំនាញ បច្ចេកវិជ្ជាជំនួយ និងអ៊ីនធឺណិត។

## ផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងថ្នាក់រៀនបរិយាប័ន្ន

ការអប់រំបរិយាប័ន្នទទួលស្គាល់សិទ្ធិរបស់កុមារ និងមនុស្សវ័យក្មេងគ្រប់រូប ត្រូវបានដាក់បញ្ចូលនៅក្នុងការការអប់រំទូទៅ ដោយគ្មានករណីលើកលែង។ ការអប់រំបរិយាប័ន្នគឺការធ្វើឱ្យសិស្សសម្របខ្លួនទៅនឹងបរិយាកាស និងវិធីសាស្ត្រនៃការបង្រៀន ដើម្បីធានាឱ្យមានការចូលរួមយ៉ាងពិតប្រាកដ និងមានតម្លៃរបស់កុមារ និងយុវជនទាំងអស់។ ក្រៅពីបញ្ហាប្រឈមទាក់ទងនឹងជំងឺកូវីដ-១៩ សិស្សពិការភ្នែកក៏បានអះអាងថាពួកគេបានប្រឈមមុខនឹងបញ្ហាមួយចំនួនទៀត។ សិស្សានុសិស្សនៅវិទ្យាល័យអប់រំពិសេស តម្រូវឱ្យសិក្សាមួយវេននៅសាលារដ្ឋ។ ដោយសារគ្រូបង្រៀននៅសាលារដ្ឋត្រូវបង្រៀនមេរៀនច្រើន ហើយមានសិស្សច្រើនក្នុងថ្នាក់ ពួកគេភាគច្រើនហាក់ដូចជាមិនសូវយកចិត្តទុកដាក់ចំពោះសិស្សដែលពិការភ្នែកនោះទេ។ ពេលខ្លះសិស្សបាត់បង់កម្លាំងចិត្តក្នុងការសិក្សានៅសាលារដ្ឋ ប៉ុន្តែពួកគេមិនមានជម្រើស។

### ចំពោះសិស្ស ពិបាកស្ដាប់

ពួកគេត្រូវការអ្នកបកប្រែភាសាសញ្ញា ដើម្បីជួយពួកគេឱ្យយល់មេរៀនកាន់តែប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេនឹងត្រូវការអ្នកបកប្រែច្រើន។

### ចំពោះសិស្ស ពិការភ្នែក

ពួកគេមានការលំបាកក្នុងការយល់ នៅពេលដែលគ្រូប្រើការបញ្ចេញសំឡេងបែបបង្ហាញ ដូចជា 'នេះ/នោះ' ដើម្បីពន្យល់ ដោយសារពួកគេមិនអាចស្រមៃមើលអ្វីដែលគ្រូកំពុងនិយាយ។

សិស្សបានអះអាងថាមិនមានការរួមបញ្ចូលគ្នានៅសាលារដ្ឋធម្មតាទេ។ ពួកគេបានបន្ថែមថា គ្រូបង្រៀននៅសាលារដ្ឋ មិនចេះភាសាសញ្ញាទាល់តែសោះ ហើយទោះបីជាពួកគាត់ធ្លាប់ចូលរួមវគ្គបណ្ដុះបណ្ដាលខ្លីៗអំពីភាសាសញ្ញាក៏ដោយ ក៏វាមិនគ្រប់គ្រាន់ដែរ។ គ្រូបង្រៀនភាគច្រើនជឿថា វាជាការល្អដែលមានអ្នកបកប្រែភាសាសញ្ញានៅក្នុងថ្នាក់នីមួយៗនៅសាលារដ្ឋធម្មតា។ វានឹងមានប្រយោជន៍សម្រាប់សិស្ស ប៉ុន្តែវានឹងត្រូវមានចំណាយច្រើន។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះផ្ដោតលើពិការភាពតែពីរប្រភេទប៉ុណ្ណោះ គឺសិស្សគ-ថ្លង់ រួមទាំងសិស្សដែលមានបញ្ហាភ្នែកមិនឃើញផងដែរ។

ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ សិស្សដែលមានពិការភាពមានអារម្មណ៍ថាខ្លួនមានផលប៉ះពាល់ច្រើនជាងសិស្សដែលមិនមានពិការភាព។ សិស្សពិការភ្នែក និងបញ្ហាក្នុងការស្ដាប់ ទទួលរងផលប៉ះពាល់ផ្លូវចិត្តដោយជំងឺកូវីដ-១៩ ដោយសារតែពួកគាត់បានជួបឧបសគ្គក្នុងការទំនាក់ទំនង មានការភ័យខ្លាច និងដោយសារកង្វះខាតនៃការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។ ចំពោះសិស្សដែលមកពីគ្រួសារជួបការលំបាកដែលទាមទារជំនួយជាអាហារ និងកន្លែងស្នាក់នៅ ទទួលរងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ។

ជំងឺកូវីដ-១៩ ក៏បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សិស្សានុសិស្សទាំងនោះ នៅពេលដែល ការរៀន និងការបង្រៀនរបស់ពួកគេត្រូវបានផ្លាស់ប្តូរ មកធ្វើតាមអ៊ីនធឺណិត នៅចំពេលដែលមានការកង្វះខាតដូចជា

- បច្ចេកវិទ្យាជំនួយ
- ជំនាញ និងចំណេះដឹងលើការប្រើប្រាស់បច្ចេកវិទ្យា
- ការគាំទ្រពីគ្រួសារ និងសហគមន៍
- ហិរញ្ញវត្ថុ

សិស្សដែលមានពិការភាពត្រូវការសេវាកម្មជាក់លាក់ និងសម្ភារៈជំនួយសម្រាប់ជីវិតប្រចាំថ្ងៃ និងការសិក្សា។ ជាងនេះទៅទៀត ថ្នាក់រៀនបរិយាប័ន្នទាមទារឱ្យមានការរៀបចំ និងការគាំទ្រដែលមានប្រសិទ្ធភាពជាងមុន ដើម្បីឱ្យសិស្សពិការភ្នែក និងសិស្សដែលពិបាកស្តាប់អាចរៀនបន្ថែម និងមិនភ័យខ្លាចក្នុងការចូលរៀន។

# អនុសាសន៍

ដើម្បីជួយដល់សិស្សក្នុងអំឡុងពេលមានវិបត្តិ ការសិក្សានេះស្នើរឱ្យមាននូវការគាំទ្រសំខាន់ពីរគឺ ការគាំទ្រផ្នែកស្មារតី និងការគាំទ្រផ្នែកការសិក្សារៀនសូត្រ។ ក្នុងអំឡុងពេលជំងឺរាតត្បាត និងការរឹតត្បិតជនដែលមានពិការភាពមានអារម្មណ៍ព្រួយបារម្ភ និងភ័យខ្លាចដោយសារតែខ្វះការគាំទ្រ និងព័ត៌មាន។

## ការគាំទ្រផ្នែកស្មារតី ♡

- ឪពុកម្តាយ និងសមាជិកគ្រួសារគួរតែព្យាយាមជួយដល់ជនដែលមានពិការភាព ដើម្បីឱ្យពួកគេមានអារម្មណ៍កក់ក្តៅ និងមានសុវត្ថិភាព។
- សមាជិកគ្រួសារគួរចំណាយពេលកាន់តែច្រើនជាមួយពួកគេ ដោយធ្វើឱ្យប្រាកដថាពួកគេមិនត្រូវបានគេទុកចោល។
- ឪពុកម្តាយ និងសហគមន៍គួរតែរៀនភាសាសញ្ញា ដើម្បីទំនាក់ទំនងជាមួយសិស្សពិបាកស្តាប់។

# ការគាំទ្រផ្នែកការសិក្សារៀនសូត្រ

១

**ទី១** សហគមន៍ សាលារៀន និងអាជ្ញាធរមូលដ្ឋាន គួរស្វែងយល់ការសិក្សាបែប ក្រុមតូចៗ (សិស្សមកជុំគ្នាដើម្បីរៀន និងធ្វើទំនាក់ទំនងក្នុងសង្គម) សម្រាប់សិស្សដែលមិនមានអ៊ីនធឺណិត ឬជំនួយពីមនុស្សពេញវ័យនៅផ្ទះ។

២

**ទី២** អាជ្ញាធរ និងគ្រូបង្រៀន គួរតែស្វែងយល់ពីការកាត់បន្ថយការចែកចាយខ្លឹមសារ និងកែសម្រួលវិធីសាស្ត្របង្រៀន។

៣

**ទី៣** ត្រូវផ្តល់ជូនការបណ្តុះបណ្តាលជាផ្លូវការសម្រាប់និស្សិត ពីអ្នកជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យាដោយមានអ្នកបកប្រែអំពីការប្រើប្រាស់វេទិកាអនឡាញមុនថ្នាក់ដំបូងត្រូវបានផ្តល់ជូន។

៤

**ទី៤** មានការផ្តល់ឧបករណ៍ និងបច្ចេកវិជ្ជាដែលមានគុណភាពខ្ពស់ចាំបាច់ និងកែលម្អលទ្ធភាពប្រើប្រាស់ និងការប្រើប្រាស់សម្ភារៈសិក្សា។ ស្ថាប័នជាច្រើនបានធ្វើមាតិកាឌីជីថល ប៉ុន្តែសិស្សដែលមានពិការភាពនៅតែមិនអាចចូលប្រើប្រាស់បានដោយសារកង្វះការសរសេរអត្ថបទ និងសំឡេងមិនច្បាស់លាស់ ព្រមទាំងមានបញ្ហាផ្សេងៗទៀត។

៥

**ជាចុងក្រោយ** រដ្ឋាភិបាល លោកគ្រូ អ្នកគ្រូ មាតាបិតា និងអ្នកជំនាញត្រូវតែពង្រឹងកិច្ចសហការ ការផ្តល់អាហារូបត្ថម្ភ និងភាពជាដៃគូក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលអប់រំក្នុងចំណោមសិស្សដែលមានពិការភាព។

មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវ និងនវានុវត្តន៍ ត្រូវបានបង្កើតឡើងជាលទ្ធផលនៃការប្តេជ្ញាចិត្តរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងគោលបំណងលើកកម្ពស់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងសកម្មភាពនៃបោះពុម្ពផ្សាយរបស់អ្នកសិក្សា និងអ្នកស្រាវជ្រាវទាំងអស់ដែលមកពីមហាវិទ្យាល័យនានានៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវ និងនវានុវត្តន៍ ធ្វើសកម្មភាពស្រាវជ្រាវជាច្រើនអំពីកម្មវិធីសិក្សារបស់មហាវិទ្យាល័យ ធ្វើសកម្មភាពស្រាវជ្រាវរួមគ្នាជាមួយនឹងសាកលវិទ្យាល័យដៃគូ រៀបចំការប្រកួតប្រជែងស្រាវជ្រាវបែបសិក្សា ផ្តល់វិញ្ញាបនបត្រសម្រាប់កម្មវិធីបណ្តុះបណ្តាល និងអនុវត្តគម្រោងស្រាវជ្រាវ។


**មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវ និងនវានុវត្តន៍**

ផ្លូវ ៩៦ Christopher Howes
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
+៨៥៥ (០) ៨១ ៨៨២ ១២២
info.researchcenter@num.edu.kh


Australian Aid

ពន្លកចំណេះ

The Asia Foundation